វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១៩ ខែតុលា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ប្រទេសកម្ពុជាកំពុងសម្លឹងមើលទីផ្សារថ្មីសម្រាប់ម្រេចកំពតក្នុងពេលដែលទិន្នផលមានការកើនឡើង
- អត្រាអតិផរណារបស់ប្រទេសចិនបានកើនខ្ពស់នៅក្នុងរយៈពេល៧ខែ
- ឱនភាពថវិការបស់សហរដ្ឋអាមេរិកបានកើនឡើងបន្ទាប់ពីការកាត់បន្ថយពន្ធ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះ-បណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជា កំពុងសម្លឹងមើលទីផ្សារថ្មីសម្រាប់ម្រេចកំពតក្នុងពេលដែលទិន្នផលមានការកើនឡើង

ផលិតកម្មម្រេចកំពតបានបន្តកើនឡើងជារៀងរាល់ឆ្នាំ។ យោងតាមការសម្ភាសន៍នៅពេលថ្មីៗ រវាងសារព័ត៌មានភ្នំពេញប៉ុស្តិ៍ជាមួយនឹងប្រធានសមាគមលើកកម្ពស់ម្រេចកំពតកម្ពុជា(KPPA) បានអោយដឹងថា ដើម្បីកាត់បន្ថយទំហំស្តុកនៃការផ្គត់ផ្គង់ដ៏ច្រើនលើសលប់ សមាគមបាននឹងកំពុងពិភាក្សាដើម្បីពង្រីកទីផ្សារថ្មីម្រេចកំពត ទៅកាន់ប្រទេសកូរ៉េខាងត្បូងនិងទីក្រុងហុងកុង។

ម្រេចកំពតគឺជាផលិតផលតែមួយគត់របស់ប្រទេសកម្ពុជាដែលបានទទួលស្លាកសញ្ញាសម្គាល់ភូមិសាស្ត្រទំនិញជាផ្លូវការ។ ផ្ទៃដីដាំដុះម្រេចមានចំនួន២៥០ហិចតាក្នុងខេត្តកំពតនិងខេត្តកែប ដែលក្នុងនោះមាន២០០ហិចតាដែលជាម្រេចទុំអាចប្រមូលផលបាន។

នៅពេលបច្ចុប្បន្ននេះ ទីផ្សារធំរបស់ម្រេចកំពតមានដូចជា៖ សហគមអឺរ៉ុប សហរដ្ឋអាមេរិក ប្រទេសជប៉ុន និងប្រទេសកាណាដា។ ចំពោះតម្លៃ ម្រេចខ្មៅមានតម្លៃ១៥ដុល្លារ/គីឡូ, ម្រេចក្រហមមានតម្លៃ២៥ដុល្លារ/គីឡូ, និងម្រេចសមានតម្លៃ២៨ដុល្លារ/គីឡូ ដែលគិតជាចំណូលជាមធ្យមប្រចាំឆ្នាំប្រហែល១លានដុល្លារ។ សមាគមលើកកម្ពស់ម្រេចកំពតកម្ពុជា(KPPA) មានសមាជិកជាកសិករចំនួន៤៤២នាក់ និងជាដៃគូជាមួយក្រុមហ៊ុនឯកជនចំនួន២៩ ក្នុងការជួយនាំចេញផលិតផលទៅកាន់ទីផ្សារអន្តរជាតិ។

### តារាងប្រចាំសប្តាហ៍៖ ទុនបម្រុងអន្តរជាតិរបស់កម្ពុជា កំពុងបន្តកើនឡើង

គណនីទុនបម្រុងអន្តរជាតិត្រូវបានប្រើប្រាស់ក្នុងការទូទាត់គណនីអន្តរជាតិ ដែលមានតួនាទីជាទ្រព្យសកម្មបម្រុង និងបង្កើតនូវគោលនយោបាយអត្រាប្តូរប្រាក់និងគោលនយោបាយរូបិយវត្ថុ (ជាពិសេស វាមានសារៈសំខាន់សម្រាប់ប្រទេសដែលប្រកាន់របបរក្សាលំនឹងអត្រាប្តូរប្រាក់ ដូចជាប្រទេសកម្ពុជាជាដើម)។

ទុនបម្រុងអន្តរជាតិរបស់ប្រទេសកម្ពុជាបានកើនឡើងពី៤ប៊ីលានដុល្លារក្នុងឆ្នាំ២០១១ ទៅ១២ប៊ីលានដុល្លារក្នុងឆ្នាំ២០១៧ដែលមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំស្មើនឹង១៨,៦% បើយោងទៅតាមទិន្នន័យសូចនាករសំខាន់ៗកម្ពុជាឆ្នាំ២០១៨របស់ធនាគារអភិវឌ្ឍអាស៊ី។ តារាងខាងក្រោមបង្ហាញពីកំណើន ក៏ដូចជាការផ្លាស់ប្តូរនៃសមាសភាគនៃទុនបម្រុង។ ទុនបម្រុងជារូបិយបណ្ណបរទេសមានចំនួន៩០%នៃទុនបម្រុងអន្តរជាតិសរុបក្នុងឆ្នាំ២០១៧ ដែលកើនឡើងពី៨២%ឆ្នាំ២០១១។ ទំហំនៃទុនបម្រុងជាមាសបានកើនឡើង ប៉ុន្តែចំនែកភាគយបានធ្លាក់ចុះពី១៥%ក្នុងឆ្នាំ២០១១ មក៥%ក្នុងឆ្នាំ២០១៧។ ក្រៅពីនេះសមាសភាគផ្សេងទៀតមានដូចជា ប្រាក់បម្រុង Special Drawing Rights(SDRs) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ដែលមានចំនែកសរុបប្រមាណពី១% ទៅ៣%ក្នុងអំឡុងពេលដូចគ្នា និងរូបិយបណ្ណបរទេសតម្កល់នៅមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលដាក់បញ្ចូលជាលើកដំបូងនៅ២ឆ្នាំមុន ប៉ុន្តែមានចំនួនតិចតួចត្រឹមតែ០,៣%នៅឆ្នាំ២០១៧។

**ទុនបម្រុងអន្តរជាតិរបស់ប្រទេសកម្ពុជា(គិតជាប៊ីលានដុល្លារ)**




ប្រភព៖ ធនាគារអភិវឌ្ឍអាស៊ី

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អត្រាអតិផរណារបស់ប្រទេសចិន បានកើនខ្ពស់នៅក្នុងរយៈពេល៧ខែ

យោងតាមការិយាល័យស្ថិតិជាតិរបស់ចិន អត្រាអតិផរណាលើតម្លៃប្រើប្រាស់បានកើនឡើង២,៥%ក្នុងខែកញ្ញា បើប្រៀបធៀបទៅនឹង១,៦%នៅក្នុងខែដដែលនៅឆ្នាំមុន ដែលតួលេខនេះគឺជាការកើនឡើងខ្ពស់បំផុតគិតក្នុងរយៈពេល៧ខែ។ ការកើនឡើងនេះបណ្តាលមកពីការកើនឡើងនូវតម្លៃម្ហូបអាហារ ដែលមានកំណើន៣,៦%។ កំណើននៃតម្លៃមានរបាយស្មើគ្នា ដោយតំបន់ទីក្រុងថ្លៃកើនឡើង២,៥%និងតំបន់ជនបទមានកំណើន២,៤%។

ការកើនឡើងនៃអត្រាអតិផរណានេះ ហាក់បីដូចជាមិនបង្កការព្រួយបារម្ភទេ ដោយសារអត្រាអតិផរណាស្នូល(ដែលដកចេញនូវថ្លៃដែលប្រែប្រួលរហ័សមួយចំនួនដូចជាថ្លៃថាមពល)បានធ្លាក់ចុះពី២%នៅខែមុន មកត្រឹម១,៧%នៅខែកញ្ញា។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ឱនភាពថវិការបស់សហរដ្ឋអាមេរិកបានកើនឡើងបន្ទាប់ពីការកាត់បន្ថយពន្ធ

ឱនភាពថវិការបស់សហរដ្ឋអាមេរិកសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៨ បានកើនឡើងដល់កម្រិតខ្ពស់ក្នុងរយៈពេល៦ឆ្នាំ ដែលមានចំនួនរហូតដល់ទៅ៧៧៩ប៊ីលានដុល្លាសហរដ្ឋអាមេរិក ដែលបានឆ្លុះបញ្ចាំងពីលទ្ធផលនៃការកាត់ពន្ធយ៉ាងខ្លាំងក្នុងឆ្នាំកន្លងទៅ បើយោងទៅតាមរបាយការណ៍ចុងឆ្នាំរបស់នាយកដ្ឋានរតនាគាជាតិអាមេរិក ដែលបានចេញផ្សាយនៅថ្ងៃច័ន្ទ។ តួលេខនេះ បានកើនឡើងចំនួន១៧% បើគិតចាប់តាំងពីឆ្នាំមុន។

ខណៈពេលដែលលោកប្រធានាធិបតី ដូណាល់ត្រាំ រំពឹងថាការកាត់ពន្ធនឹងជម្រុញសកម្មភាពសេដ្ឋកិច្ច លទ្ធផលបង្ហាញថា ការរំពឹងទុកដែលថាថវិកាសារពើពន្ធមានចីរភាពតាមរយៈការបង្កើននូវកំណើនសេដ្ឋកិច្ច ហាក់បីដូចជាមិនសូវជាដំណើរការទេ ។

ការចំណាយនៃការធ្វើហិរញ្ញប្បទានទៅលើបំណុលរបស់សហរដ្ឋអាមេរិកកំពុងតែបន្តកើនឡើង ហើយអ្នកសេដ្ឋកិច្ចជាច្រើនបានព្យាករណ៍ថា ការធ្វើបែបនេះអាចនឹងប៉ះពាល់ដល់សេដ្ឋកិច្ច។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាកំណើនសេដ្ឋកិច្ចនិងអត្រាអតិផរណារបស់សហរដ្ឋអាមេរិក និងអត្រាអតិ-

ផរណា អត្រានិកម្មភាព សមតុល្យពាណិជ្ជកម្ម និងសមតុល្យថវិកា នៅក្នុងប្រទេសដែលជាសមាជិកអាស៊ានសំខាន់មួយចំនួន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី២២ ខែតុលា

- តុល្យភាពថវិការបស់ហ្វីលីពីន សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែកញ្ញា
- កំណើនឥណទានរបស់ឥណ្ឌូនេស៊ី សម្រាប់ខែកញ្ញា
- សន្ទស្សន៍រាល់សម្មភាពឧស្សាហកម្មរបស់ជប៉ុន សម្រាប់ខែសីហា
- អត្រានិកម្មភាពរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា

ថ្ងៃអង្គារ ទី២៣ ខែតុលា

- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតរបស់កូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់សិង្ហបុរី សម្រាប់ខែកញ្ញា
- ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា
- ទិន្នន័យការលក់រាយរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែកញ្ញា

ថ្ងៃពុធ ទី២៤ ខែតុលា

- ទិន្នន័យនៃការផ្លាស់ប្តូរស្តុកប្រេងឆៅ(API)របស់អាមេរិក ក្នុងថ្ងៃទី១៩ ខែតុលា
- អត្រាអតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែកញ្ញា
- សន្ទស្សន៍រួមគ្នានៃសូចនាករសេដ្ឋកិច្ច(coincident index) របស់ជប៉ុន សម្រាប់ខែសីហា
- ទិន្នន័យការផ្គត់ផ្គង់រូបិយវត្ថុ(M2)របស់តៃវ៉ាន់ សម្រាប់ខែកញ្ញា

ថ្ងៃព្រហស្បតិ៍ ទី២៥ ខែតុលា

- អត្រាកំណើនផ.ស.សរបស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ទិន្នន័យការវិនិយោគសញ្ញាបណ្ណនិងភាគហ៊ុនបរទេសរបស់ជប៉ុន សម្រាប់ថ្ងៃទី២០ ខែតុលា
- សន្ទស្សន៍រួមគ្នានៃសូចនាករសេដ្ឋកិច្ច និងសន្ទស្សន៍សូចនាករសេដ្ឋកិច្ចនាំមុខគេរបស់ម៉ាឡេស៊ី សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មផ្នែកទំនិញរបស់អាមេរិច សម្រាប់ខែកញ្ញា

ថ្ងៃសុក្រ ទី២៦ ខែតុលា

- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់របស់កូរ៉េខាងត្បូង សម្រាប់ខែតុលា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកប្រើប្រាស់(CPI)តូក្យូរបស់ជប៉ុន សម្រាប់ខែតុលា
- អត្រានិកម្មភាពរបស់សិង្ហបុរី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ផលិតកម្មឧស្សាហកម្មរបស់សិង្ហបុរី សម្រាប់ខែកញ្ញា
- សន្ទស្សន៍តម្លៃអចលនទ្រព្យរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- អត្រាកំណើនផ.ស.សរបស់អាមេរិក សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ទិន្នន័យទុនបម្រុងរូបិយប័ណ្ណបរទេសរបស់ឥណ្ឌា សម្រាប់ថ្ងៃទី១៩ ខែតុលា ៕

****************************